ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៧២

ចុះថ្ងៃទី ៣០-០១-២០១២

សាលដីកា

លេខ ៖ ៥៥ "ក្រ.III.ស"

ចុះថ្ងៃទី ០៦-០៨-២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៧២ ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១២ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted]ភ័សនា ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរបើកបររថយន្ត កើតនៅសង្កាត់លេខ ២ រាជធានីភ្នំពេញ ទីលំនៅមុនពេលឃ[redacted] ក្រុមទី១៣ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] (ស) ម្ដាយឈ្មោះ [redacted](រ) ប្រពន្ធឈ្មោះ [redacted] មានកូន ៣នាក់ ទោសគ្មានពីមុន ឃុំខ្លួនថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០១១។

មានលោក គិន វិបុល ជាមេធាវីការពារ។

ជាប់ចោទពីបទ: ឆបោក ក្លែងបន្លំឯកសារសាធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង ប្រព្រឹត្តនៅសង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៧៧, ៣៧៨ និងមាត្រា ៦២៩, ៦៣០ នៃក្រមព្រហ្មទណ្ឌ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted] ហុង ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ មុខរបរពាណិជ្ជករ ទីលំនៅសព្វថ្ងៃផ្ទះលេខ ១៧១E០ ផ្លូវលេខ ២១៥ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ។





Scanned with CamScanner

# ឯដំណើររឿងមានដូចតទៅ

កាលពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១០ ឈ្មោះ[redacted]ភ័សនា ភេទប្រុស អាយុ ៣៧ឆ្នាំ បានមកខ្ចីប្រាក់ពីឈ្មោះ[redacted]ហុង ចំនួន ៦៥.០០០ដុល្លាអាមេរិក ហើយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីផ្ទះចំនួន ០២ច្បាប់ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០១០ មានប្រថាប់ត្រាសង្កាត់ក្រាំងធ្នង់ និងមានហត្ថលេខា និងឈ្មោះ [redacted] រស់ ជាចៅសង្កាត់ឲ្យទៅឈ្មោះ [redacted] ហុង។ ក្រោយពីបានទទួលលិខិតផ្ទេរសិទ្ធិកាន់កាប់ដី-ផ្ទះរួច ឈ្មោះ[redacted] ហុង បានទំនាក់ទំនងជាមួយមូលដ្ឋានទើបដឹងថា លិខិតដូចខាងលើនេះក្លែងក្លាយ ដោយអាជ្ញាធរសង្កាត់ក្រាំងធ្នង់បានបញ្ជាក់តាមលិខិត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១១ ថា លិខិតផ្ទេរសិទ្ធិគ្មានលេខ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០១០ លើដីឡូត៍លេខ ៥៩ និងលេខ ៦០ ស្ថិតនៅភូមិវិមានទ្រង់ សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលបានផ្ទេរពីឈ្មោះ[redacted]ភ័សនា ផ្ទេរសិទ្ធិឲ្យឈ្មោះ [redacted]ហុង នោះពុំមែនជាលិខិតផ្ទេរសិទ្ធិកាន់កាប់ដីឡូត៍ក្នុងសង្កាត់ក្រាំងធ្នង់ឡើយ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១២៣ (កប៥) ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ផ្តន្ទាទោសឈ្មោះ[redacted]ភ័សនា ភេទប្រុស អាយុ ៣៧ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៥ឆ្នាំ (ប្រាំឆ្នាំ) និងពិន័យជាប្រាក់ចំនួន ៣,០០០,០០០រៀល(បីលានរៀល) ពីបទ ឆបោក ក្លែងបន្លំឯកសារសាធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង ប្រព្រឹត្តនៅសង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ មាត្រា ៣៧៨ និងមាត្រា ៦២៩ មាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ។

២- បង្គាប់ឲ្យឈ្មោះ[redacted]ភ័សនា សងប្រាក់ចំនួន ៦៥.០០០ដុល្លា(ប្រាំមួយម៉ឺនប្រាំពាន់ដុល្លាអាមេរិក) និងសំណងជម្ងឺចិត្តចំនួន ៥.០០០.០០០រៀល(ប្រាំលានរៀល) ទៅឲ្យឈ្មោះ [redacted] ហុង ជាដើមបណ្តឹងរដ្ឋប្បវេណី សំណូមពរលើសពីនេះបដិសេធចោល។

៣- វត្ថុតាងដូចក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ៥៥១ វត ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១១ មានៈ

- ទូរស័ព្ទដៃម៉ាកណូគាសេរី E7 ស៊ីមពីរ (ចិន) ចំនួន ០១គ្រឿង, លុយចំនួន ១១.០០០រៀល។
- ម៉ូតូមួយគ្រឿងម៉ាកហុកដា AX ពណ៌ទឹកប៊ិចចាស់ ពាក់ស្លាកលេខ ភ្នំពេញ 1AO.៤៥៦១ ចំនួន ០១គ្រឿង។
- នាឡិកាដៃម៉ាកអូម៉េហ្គាមុខស(ខ្សែដែក) ចំនួន ០១គ្រឿង។
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឈ្មោះ[redacted]ភ័សនា ត្រូវប្រគល់ឲ្យម្ចាស់ដើមយកទៅប្រើប្រាស់វិញ។
- សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០១១ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។៚



Scanned with CamScanner

- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៤៧ ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០១២ របស់លោក [redacted] សមិទ្ធិ ~~ជា~~មេធាវីតំណាង និងទទួលសិទ្ធិប្តឹងឧទ្ធរណ៍ពីឈ្មោះ [redacted] ភ័សនា ជាជនជាប់ចោទ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១២៣ (កប៥) ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហុង បានឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ។

ជនជាប់ចោទឈ្មោះ [redacted] ភ័សនា ឆ្លើយថា: ខ្លួនប្តឹងឧទ្ធរណ៍មកនេះដើម្បីសុំឲ្យលោកប្រធានបន្ធូរបន្ថយទោស ព្រោះខ្លួនបានដឹងកំហុសខ្លួនហើយ។ រាល់លិខិតត្រាខ្លួនធ្វើខ្លួនឯងទាំងអស់ ខ្លួនបានធ្វើតែម្តងនេះទេ ត្រាខ្លួនបោះចោលហើយ។ ខ្លួនខ្ចីលុយដើមបណ្តឹងរដ្ឋប្បវេណីបាន ខ្លួនបានបង់ការប្រាក់រាល់ខែ លុះឈ្មោះ សុខគា បានបោកខ្លួន ខ្លួនអត់មានប្រាក់សងគាត់ក៏ប្តឹងខ្លួន ខ្លួនក្លែងឯកសារដើម្បីខ្ចីប្រាក់។ ការប្រាក់ខ្លួនបង់រហូតបាន ៧ ទៅ ៨ខែ (ក្នុងមួយខែបង់ប៉ុន្មានខ្លួនមិនចាំទេ)។ សំណូមពរ សុំក្រុមប្រឹក្សាបន្ធូរបន្ថយទោសឲ្យខ្លួនផង។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

បណ្តឹងឧទ្ធរណ៍របស់លោក[redacted]សមិទ្ធិ មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] ភ័សនា បានធ្វើឡើងត្រឹមត្រូវតាមច្បាប់ យោងមាត្រា ៣៧៥ មាត្រា ៣៧៦ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ភ័សនា ដូចបទចោទរបស់អយ្យការសាលាដំបូង (ចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយសាក្សី [redacted] សេន ស៊ីសង្វាក់ជាមួយចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី)។

សាលក្រមព្រហ្មទណ្ឌលេខ ១២៣ (កប៥) ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសម្រេចមកនេះ ឃើញថា មានសំអាងហេតុ និងសេចក្តីសម្រេចត្រឹមត្រូវតាមច្បាប់ ហើយគួរតម្កល់ទុកជាបានការ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

នៅក្នុងរឿងនេះកូនក្តីខ្លួនបានឆ្លើយសារភាពតាំងពីដើមមក ហើយស៊ីសង្វាក់ជាមួយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី។ កូនក្តីខ្លួនប្តឹងឧទ្ធរណ៍សុំស្ថានសម្រាល ដោយសាលាដំបូងផ្តន្ទាទោសកូនក្តីខ្លួនធ្ងន់ ខ



Scanned with CamScanner

ធូរពេក។ ការដែលកូនក្តីខ្លួនធ្វើលិខិតទាំងអស់ ព្រោះដើម្បីធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីទុកចិត្ត ព្រោះចង់បានប្រាក់ដើម្បីរកស៊ី ហើយបន្ទាប់ពីខ្ចីប្រាក់ កូនក្តីខ្លួនបានបង់ការប្រាក់រហូតមក។ តាមមាត្រា ៩៣ មាត្រា ៩៤ សូមផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួនដែលបានជាប់ពន្ធនាគារមួយរយៈ តាមមាត្រា ១០៣ មាត្រា ១០៤ និងសុំចោលប្រាក់ពិន័យចោល តាមមាត្រា ៩៧ មាត្រា ៩៨ ដោយគាត់មានប្រពន្ធ កូនតូច។ សំណូមពរ សុំក្រុមប្រឹក្សាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនដោយអនុគ្រោះ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍លេខ ៤៧ ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០១២ របស់លោក យិន សមិទ្ធិ មេធាវីទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ[redacted]ភ័សនា ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- ជនជាប់ចោទបានឆ្លើយសារភាពដោយបញ្ជាក់ច្បាស់លាស់ថា ខ្លួនពិតជាបានធ្វើលិខិតផ្ទេរសិទ្ធិពីខ្លួន ([redacted] ភ័សនា) ទៅឲ្យឈ្មោះ [redacted] ហុង ជាជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីមែន ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីជឿជាក់ ហើយព្រមប្រគល់ប្រាក់មកឲ្យខ្លួនចំនួន ៦៥.០០០(ប្រាំមួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក។ លិខិតនោះខ្លួនជាអ្នកធ្វើដោយខ្លួនឯង ឯហត្ថលេខាអាជ្ញាធរ និងត្រា ក៏ខ្លួនធ្វើដោយខ្លួនឯងដែរ។ ប្រាក់ដែលខ្លួនបានទទួលសិទ្ធិពីដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៥.០០០(ប្រាំមួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ប្រាកដមែន។

៣- មានភស្តុតាងបញ្ជាក់ពិរុទ្ធភាពលើជនជាប់ចោទ ពីបទ ឆបោក ក្លែងឯកសារសាធារណៈ និងប្រើប្រាស់ឯកសារសាធារណៈ ប្រព្រឹត្តនៅសង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០១០ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៧៧, ៣៧៨, ៦២៩ និងមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ។

៤- សាលក្រមព្រហ្មទណ្ឌលេខ ១២៣ (កប៥) ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ។



Scanned with CamScanner

# ហេតុដូច្នេះ

# វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៤៧ ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០១២ របស់លោក[redacted] សមិទ្ធិ មេធាវីទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ[redacted] ភ័សនា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១២៣ (កប៥) ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល។

៣- បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៣ ប្រកាសជាសាធារណៈនៅថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ បើកផ្លូវសាទុក្ខ ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះទៅ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី 18 ខែ ០2 ឆ្នាំ ២០១៤

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner